**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ : ០៦៨ សសរ.កសក

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារសហប្រតិបត្តិការ រវាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ កម្ពុជា និងក្រសួងកសិកម្ម ចិន

## រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញលិខិត ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ២០០៣ របស់ក្រសួងកសិកម្ម ចិន
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## <u>ស ម្រេ ច</u>

**<u>ប្រការ ១</u>** : សំរេចចាត់តាំងឯកឧត្តម **ឌុំ សារ៉ុន** អគ្គនាយក នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ជាអ្នកសំរបសំរួល (Focal Point) រវាងក្រសួកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កម្ពុជា ជាមួយនិងក្រសួងកសិកម្ម ចិន ។

**<u>ប្រការ ២</u>**: បង្កើតក្រុមការងារមួយដែលមានសមាភាពដូចខាងក្រោម :

១- លោក **នួត សារ៉ាវុធ** អនុប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ ជាប្រធាន

២- លោក **ស៊ុន ចាន** ប្រធានការិយាល័យសហប្រតិបត្តិការអន្តរជាតិ នៃនាយកដ្ឋានផែនការ ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ ជាអនុប្រធាន

៣- លោក **ខួន ហួត** មន្ត្រី ការិយាល័យសហប្រតិបត្តិការអន្តរជាតិ នៃនាយកដ្ឋានផែនការ ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក

**ប្រការ ៣ :** អំពីភារកិច្ចរបស់ក្រុមការងារ :

ក- ក្រុមការងារមានភារកិច្ចសម្របសម្រួលរាល់កិច្ចសហប្រតិបត្តិការរវាងក្រសួងកសិកម្មចិន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ កម្ពុជា អោយមានប្រសិទ្ធិភាពខ្ពស់ ។

ខ- ក្រុមការងារមានភារកិច្ចសិក្សា កសាងគំរោងនានា លើវិស័យកសិកម្ម ដើម្បីធ្វើកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ជាមួយក្រសួងកសិកម្ម ចិន ។

**ប្រការ ៤ :** ក្រុមការងារ ត្រូវជួបប្រជុំគ្នាទៀងរាល់ខែ ក្នុងមួយខែម្តង ឬតាមការចាំបាច់ របស់ប្រធានក្រុមការងារ ។ អស់លោក- លោកស្រី ជាសមាជិកក្រុមការងារត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ ។

**ប្រការ ៥ :** អគ្គនាយក នៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន ផែនការ ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋាន គណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋាន បុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ និងប្រការ២ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតនេះទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ ២០០៣

រដ្ឋមន្ត្រី

ច័ន្ទ-សារុន

**កន្លែងទទួល** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

"ដើម្បីជូនជ្រាប"

- ដូចប្រការ ៥

"ដើម្បីអនុវត្ត"

- ឯកសារ-កាលប្បវត្តិ